# ច្បាប់

# ស្តីពី

## ការផ្តន្ទាទោសការកាន់អាវុធ
## និងការពាក់សំលៀកបំពាក់
## ឯកសណ្ឋាន ដោយខុសពីបទបញ្ជា



Downloaded from http://www.khmerlaws.com

**ក្រុមប្រឹក្សារដ្ឋ/រដ្ឋសភា**

**ក្រឹត្យ/ច្បាប់/១១ ក្រ/០៧ កុម្ភៈ ១៩៩២/ស្តីពី ការផ្តន្ទាទោសការកាន់កាប់អាវុធ និងការពាក់សំលៀកបំពាក់ឯកសណ្ឋាន ដោយខុសពីបទបញ្ជា**

**ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

**សំរេច**

ប្រកាសអោយប្រើច្បាប់ស្តីពីការផ្តន្ទាទោសការកាន់អាវុធ និងការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២ នាសម័យប្រជុំសាមញ្ញ លើកទី២២ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ.ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩២

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និងត្រា

ហេង សំរិន



Downloaded from http://www.khmerlaws.com

# ច្បាប់
# ស្តីពី
# ការផ្តន្ទាទោសការកាន់អាវុធ និង
# ការពាក់សំលៀកបំពាក់ឯកសណ្ឋាន ដោយខុសពីបទបញ្ជា

**មាត្រា ១.-**

ជនណាដែលគ្មានសិទ្ធិពាក់សំលៀកបំពាក់ឯកសណ្ឋានតាមបទបញ្ជាណាមួយ ហើយពាក់សំលៀកបំពាក់ឯកសណ្ឋាននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ។

ជនណាដែលពាក់ស័ក្តិដែលខ្លួនគ្មានសិទ្ធិពាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ។

សំលៀកបំពាក់ឯកសណ្ឋានតាមបទបញ្ជាគឺ : សំលៀកបំពាក់សំរាប់អ្នកបួសក្នុងសាសនា និងសំលៀកបំពាក់សំរាប់អ្នករដ្ឋការ យោធិន នគរបាល ឬស៊ីវិលដែលមានកំណត់ក្នុងអត្ថបទជាធរមាន ។

**មាត្រា ២.-**

ជនណាដែលកាន់កាប់ លក់ ទិញ រក្សាទុកដោយគ្មានលិខិតអនុញ្ញាតត្រឹមត្រូវ នូវគ្រឿងផ្ទុះ គ្រាប់រំសេវ កាំភ្លើងគ្រប់ប្រភេទ លើកលែងតែកាំភ្លើងខ្យល់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

**មាត្រា ៣.-**

ជនណាដែលបានអោយ បានអោយខ្ចី ឬបានជួលកាំភ្លើង គ្រឿងផ្ទុះ ឬគ្រាប់រំសេវដែលខ្លួនមានលិខិតកាន់កាប់ត្រឹមត្រូវ ទៅជនដែលគ្មានការអនុញ្ញាតតាមបទបញ្ជា ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២នៃច្បាប់នេះ ។

**មាត្រា ៤.-**

ជនណាផលិតកាំភ្លើង គ្រឿងផ្ទុះ ឬគ្រាប់រំសេវដូចមានចែងក្នុងមាត្រា ២ នៃច្បាប់នេះ ដោយគ្មានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

**មាត្រា ៥.-**

វត្ថុតាងនៃបទល្មើសដែលមានចែងក្នុងមាត្រា២ និងមាត្រា៤ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

**មាត្រា ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២ នាសម័យប្រជុំ សាមញ្ញលើកទី២២ នីតិកាលទី១ ។



Downloaded from http://www.khmerlaws.com

ធ្វើនៅភ្នំពេញ.ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២

ជ.រដ្ឋសភា

ប្រធាន

ហត្ថលេខា និងត្រា

ជា ស៊ីម



Downloaded from http://www.khmerlaws.com